ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១០..អនក្រ..

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចំពោះកិច្ចដើម្បីទទួលយកពលរដ្ឋអាហ្វហ្គានីស្ថាន មកស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ .**

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីទទួលយកពលរដ្ឋអាហ្វហ្គានីស្ថានដែលជាបុគ្គលិកអង្គការមូលនិធិអាស៊ី និងក្រុមគ្រួសារមកស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ *ប្រធាន*

២. ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ចំន្ទថារិទ្ធ** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ *អនុប្រធានអចិន្ត្រៃយ៍*

៣. ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូរ៉ាន់** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ *អនុប្រធាន*

| | | | |
|---|---|---|---|
| ៤. លោក | **យស សុខេមរិន** | អនុប្រធាននាយកដ្ឋានកិច្ចការកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | *អនុប្រធាន* |
| ៥. ឯកឧត្តម វេជ្ជបណ្ឌិត | **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេស ក្រសួងសុខាភិបាល | *សមាជិក* |
| ៦. ឯកឧត្តម នាយឧត្តមសេនីយ៍ | **សុ ម៉ាន់នី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | *សមាជិក* |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុំ សុខឃី** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | *សមាជិក* |
| ៨. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ា ឈុះជា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | *សមាជិក* |
| ៩. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ ទាសនា** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | *សមាជិក* |
| ១០. ឯកឧត្តម | **នួន ផារ័ត្ន** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | *សមាជិក* |
| ១១. លោក | **ម៉ាន់ ចន្ធី** | ប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | *សមាជិក* |
| ១២. ឧត្តមសេនីយ៍ឯក | **យូ សារុំ** | ប្រធាននាយកដ្ឋានជនភៀសខ្លួន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | *សមាជិក* |
| ១៣. ឧត្តមសេនីយ៍ទោ | **ជុំ ពិសុធ** | ជំនួយការ ឯកឧត្តមអគ្គនាយកអន្តោប្រវេសន៍ | *សមាជិក* |

**ប្រការ ២ .**_

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ និងសម្របសម្រួលផ្ដល់ការអនុញ្ញាតឱ្យពលរដ្ឋអាហ្វហ្គានីស្ថានដែលជាបុគ្គលិកអង្គការមូលនិធិអាស៊ី និងក្រុមគ្រួសារចូល និងស្នាក់នៅបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ស្ដីពីអន្តោប្រវេសន៍ និងគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា
- សម្របសម្រួលដល់ការអនុវត្តវិធានការរបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅពេលដែលពលរដ្ឋអាហ្វហ្គានីស្ថានមកដល់ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ ជ្រើសរើស ទីកន្លែងស្នាក់នៅបណ្ដោះអាសន្ន
- សម្របសម្រួលជាមួយក្រុមហ៊ុនអាកាសចរដើម្បីបង្កលក្ខណៈដល់ការដឹកជញ្ជូនមកកាន់ប្រទេសកម្ពុជា និងរៀបចំមធ្យោបាយដឹកជញ្ជូនពីអាកាសយានដ្ឋានទៅកន្លែងស្នាក់នៅ និងនៅពេលចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិក្នុងការរៀបចំគ្រប់គ្រងការស្នាក់នៅ និងការពារសន្តិសុខ សុវត្ថិភាពក្នុងពេលស្នាក់នៅបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ដើម្បីណែនាំ អប់រំ អំពីវប្បធម៌ ទំនៀមទំលាប់ប្រពៃណីខ្មែរ និងព័ត៌មាននានាទាក់ទងទៅនឹងជីវភាពសង្គម ក្នុងអំឡុងពេលនៃការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បង្កលក្ខណៈសម្រាប់ធ្វើការសម្ភាសន៍នានា ដើម្បីស្វែងរកការតាំងទីលំនៅនៅប្រទេសទីបី



ß

- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារជូន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និងផ្តល់យោបល់ដឹកនាំ
- រៀបចំឯកសារពាក់ព័ន្ធជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣ ._**

ប្រធានក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៤ ._**

ក្រុមការងារនេះ ត្រូវបំពេញការងារក្រោមការដឹកនាំ ណែនាំដោយផ្ទាល់ពី សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់ខ្លួន និងអាចប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីជួយបំពេញការងារតាមការចាំបាច់។

អនុប្រធាន និងសមាជិកក្រុមការងារត្រូវបំពេញការងារតាមការចាត់តាំង និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

*ថ្ងៃ ចន្ទ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ